**សេចក្តីជូនដំណឹងនេះត្រូវតែបានផ្តល់ជូនអ្នកក្រោមច្បាប់នៃរដ្ឋកាលីហ្វ័រញ៉ា**

អ្នកបានទទួលការថែទាំជម្ងឺក្នុងភាពអាសន្ននៅក្នុងមន្ទីរពេទ្យមួយ ដែលមិនមែនជាផ្នែកនៃបណ្តាញអ្នកផ្តល់កិច្ចបម្រើរបស់ផែនការសុខភាពរបស់អ្នកឡើយ។ នៅក្រោមច្បាប់រដ្ឋ, ការថែទាំជម្ងឺក្នុងភាពអាសន្នត្រូវតែបានរ៉ាប់រងបង់ថ្លៃជូនដោយផែនការសុខភាពរបស់អ្នក ដោយគ្មានល័ក្ខខ័ណ្ឌកំណត់ថាតើអ្នកបានទទួលការថែទាំជម្ងឺនៅទីណានោះឡើយ។ វេជ្ជបណ្ឌិតដែលកំពុងថែទាំជម្ងឺជូនអ្នកបានសម្រេចថា អ្នកអាចត្រូវផ្ទេរដោយសុវត្ថិភាព ទៅកាន់មន្ទីរពេទ្យផ្សេងមួយទៀតសម្រាប់ទទួលការថែទាំសុខភាពបន្ថែម ដែលអ្នកត្រូវការ។ ដោយសារអ្នកបានចាកផុតពីការថែទាំជម្ងឺក្នុងភាពអាសន្ននេះរួចហើយ, នោះផែនការសុខភាពរបស់អ្នកមិនបានអនុញ្ញាតឲ្យអ្នកនៅបន្តទទួលការថែទាំជម្ងឺក្នុងមន្ទីរពេទ្យនេះតទៅទៀតឡើយ។ ផែនការសុខភាពរបស់អ្នកបានរៀបចំ ឲ្យគេផ្ទេររូបអ្នក ទៅកាន់មន្ទីរពេទ្យមួយទៀត ដែលស្ថិតក្នុងបណ្តាញអ្នកផ្តល់កិច្ចបម្រើរបស់ផែនការសុខភាពរបស់អ្នក។ បើអ្នកយល់ព្រមឲ្យគេផ្ទេរ, នោះផែនការសុខភាពរបស់អ្នកនឹងរ៉ាប់រងបង់ថ្លៃការថែទាំជម្ងឺរបស់អ្នកក្នុងមន្ទីរពេទ្យនោះ។ អ្នកនឹងត្រូវបង់តែថ្លៃបដិភាគ, ថ្លៃបង់រង, ឬថ្លៃធានារ៉ាប់រង-រងសម្រាប់ការថែទាំជម្ងឺប៉ុណ្ណោះ។ អ្នកនឹងមិនត្រូវបង់ថ្លៃបដិភាគ, ថ្លៃបង់រង, ឬថ្លៃធានារ៉ាប់រង-រងសម្រាប់ថ្លៃដឹកជញ្ជូនទៅកាន់មន្ទីរពេទ្យមួយទៀត ដែលបានរ៉ាប់រងដោយផែនការសុខភាពរបស់អ្នកនោះឡើយ។

**បើអ្នកជ្រើសរើសបន្តស្នាក់នៅក្នុងមន្ទីរពេទ្យនេះ ដើម្បីទទួលការថែទាំជម្ងឺបន្ថែមទៀត, នោះអ្នកនឹងត្រូវបង់ថ្លៃការថែទាំពេញតម្លៃដោយខ្លួនឯង ពីព្រោះឥឡូវនេះអ្នកលែងត្រូវការការថែទាំជម្ងឺក្នុងភាពអាសន្នទៀតហើយ។** តម្លៃនេះអាចសរុបមាននូវតម្លៃវេជ្ជបណ្ឌិតម្នាក់ ឬវេជ្ជបណ្ឌិតច្រើននាក់, តម្លៃមន្ទីរពេទ្យ, និងតម្លៃមន្ទីរពិសោធន៍, តម្លៃការព្យាបាលដោយវិទ្យុសកម្ម, ឬមួយក៏តម្លៃសេវាកម្មដទៃៗផ្សេងទៀត ដែលអ្នកទទួល។ បើអ្នកគិតថាការផ្ទេរនេះមិនអាចផ្តល់សុវត្ថិភាពជូនអ្នកបានទេ, នោះចូរពិគ្រោះជាមួយវេជ្ជបណ្ឌិតអំពីកង្វល់ផងទាំងឡាយរបស់អ្នក។ បើអ្នកត្រូវការជំនួយផ្សេងៗជាបន្ថែមទៀត, នោះអ្នកអាចទាក់ទង ៖

- ក្រសួងសេវាសមាជិកនៃផែនការសុខភាពរបស់អ្នក។ ចូរពិនិត្យមើលលើប័ណ្ណសមាជិកនៃផែនការសុខភាពរបស់អ្នក ដើម្បីរកមើលលេខទូរស័ព្ទនោះ។ អ្នកអាចដាក់បណ្តឹងសាទុក្ខជាមួយផែនការសុខភាពរបស់អ្នកបាន។
- មជ្ឈមណ្ឌលជំនួយរបស់ក្រសួងគ្រប់គ្រងការថែទាំសុខភាព (Department of Managed Health Care’s Help Center) តាមលេខ 1-888-466-2219 ។ មជ្ឈមណ្ឌលជំនួយរង់ចាំបម្រើការ 24 ម៉ោងក្នុងមួយថ្ងៃ, 7 ថ្ងៃក្នុងមួយអាទិត្យ។ មជ្ឈមណ្ឌលជំនួយអាចធ្វើការជាមួយផែនការសុខភាពរបស់អ្នក ដើម្បីជួយដោះស្រាយកង្វល់ផ្សេងៗរបស់អ្នក, ប៉ុន្តែអ្នកអាចនៅតែបន្តបង់ថ្លៃការថែទាំជម្ងឺក្នុងមន្ទីរពេទ្យនេះពេញតម្លៃដោយខ្លួនឯង ប្រសិនបើអ្នកសម្រេចបន្តស្នាក់នៅទីនេះ។

បើអ្នកមានផែនការសុខភាពមេឌីឃារ (Medicare), នោះអ្នកមានសិទ្ធិធ្វើឧទ្ធរណ៍បន្ថែម។ បើផែនការសុខភាពមេឌីឃារសម្រេចបញ្ជូនអ្នក ឲ្យទៅកាន់មន្ទីរពេទ្យមួយផ្សេងទៀត, នោះអ្នកអាចស្នើសុំធ្វើឧទ្ធរណ៍ឆាប់រហ័ស( លឿន )ស្តីអំពីសេចក្តីសម្រេចរបស់វាបាន។ ផែនការសុខភាពរបស់អ្នកត្រូវតែផ្តល់ជូនអ្នកនូវសេចក្តីសម្រេចមួយដោយឆាប់រហ័ស។ បើអ្នកចង់ស្នើសុំធ្វើឧទ្ធរណ៍, ចូរទូរស័ព្ទទាក់ទង ឬផ្ញើទូរសារទៅផែនការសុខភាពរបស់អ្នក, ហើយស្នើសុំធ្វើឧទ្ធរណ៍ឆាប់រហ័យមួយឡើង។ មនុស្សទីទៃ, ដូចជាសាច់ញាតិ ឬវេជ្ជបណ្ឌិតរបស់អ្នក, អាចជួយទូរស័ព្ទទាក់ទង ឬផ្ញើទូរសារជូនអ្នកបាន។ វេជ្ជបណ្ឌិត ឬមិត្តភក្តិ/សាច់ញាតិអាចជួយទូរស័ព្ទទាក់ទង ឬផ្ញើទូរសារជូនអ្នកបាន ប្រសិនបើអ្នកផ្តល់សេចក្តីអនុញ្ញាតជូនពួកគេជាលាយលក្ខណ៍អក្សរ – ដែលការអនុញ្ញាតបែបនេះត្រូវគេហៅថា **ការផ្តល់សិទ្ធិអនុញ្ញាត** (authorization) ។ បើឧទ្ធរណ៍របស់អ្នកត្រូវគេបដិសេធ, នោះមេឌីឃារនឹងរកអ្នកពិនិត្យពីក្រៅផែនការសុខភាពរបស់អ្នក ឲ្យចូលមកពិនិត្យមើលសំណុំរឿងរបស់អ្នកឡើងវិញជាស្វ័យប្រវត្ត។ បើអ្នកមិនយល់ស្របជាមួយសេចក្តីសម្រេចរបស់អ្នកពិនិត្យរូបនោះទេ, នោះអ្នកនឹងត្រូវបានជម្រាបប្រាប់ ឲ្យដឹងអំពីសិទ្ធិឧទ្ធរណ៍បន្ថែមៗទៀត។